# ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣២៥

## ស្តីពី

## រូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រវាត់ក សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន

### យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៧

ROYAUME DU CAMBODGE
SECRETARIAT DU PALAIS ROYAL

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា សម្រាប់សម្គាល់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលបម្រើការនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២

## រូបសញ្ញាអប់រំ យុវជន និងកីឡា

**មាត្រា២.-**

រូបសញ្ញាអប់រំ យុវជន និងកីឡា ត្រូវបានកំណត់ដូចតទៅ ÷

- មានរាងរង្វង់មូល ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាស

- មានទទឹងប្រវែង ៤ភាគ៥ នៃកម្ពស់

- ផ្ទៃកខាងក្នុងរង្វង់មូលមានផ្ទៃពណ៌ផ្ទៃមេឃ ដែលរំលេចដោយកាំរស្មីពណ៌មាស ចាំងបំភ្លឺគ្រប់ទិសទី

-នៅខាងក្រោមចំកណ្តាល មានកំណាត់ខ្សែបូពណ៌ផ្ទៃមេឃ និងគែមពណ៌មាសដែលចារឹក ដោយអក្សរពណ៌មាស ថា ក្រសួងអប់រំ យុវជន និងកីឡា

- នៅចំកណ្តាល ពីលើកម្រងផ្កាក្បាច់ភ្ញីទេស មានកងរង្វង់មូលទ្រភ្លើងគុបពណ៌មាស ។

រូបសញ្ញាអប់រំ យុវជន និងកីឡា សម្រាប់ប្រើប្រាស់ជាផ្លូវការ និងដាក់លើសក្តិស្មា សក្តិចុងកអាវ សក្តិចុងដៃអាវ និងដាក់នៅលើ សក្តិខ្ទាស់លើអាវបុរស ឬ លើក្រមាពានារបស់នារី នៃមន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និង ក្របខ័ណ្ឌគ្រូបង្រៀន កម្រិតមូលដ្ឋាន ។

រូបសញ្ញាអប់រំ យុវជន និងកីឡានេះ មានរូបភាពដូចក្នុងឧបសម្ព័ន្ធទី១ ។

## ជំពូកទី៣

## សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា នៃមន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន

### ផ្នែកទី១

### អំពីសញ្ញាសក្តិ

ROYAUME DU CAMBODGE * LE ... ROYAL

**មាត្រា៣.-**

សញ្ញាសក្តិមន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ត្រូវបានកំណត់ដូចតទៅ ÷

**ក- ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម**

**១- អំពីសក្តិស្មា**

សក្តិស្មា មានផ្ទៃកម្ទីពណ៌ខៀវទឹកប៊ិច រចនាតុបតែង ដោយក្បាច់ភ្ញីទេសពីរទងពណ៌មាស មួយវែង មួយខ្លី និងមានផ្កាមួយនៅលើទងវែង និងផ្លែពីរ។ នៅពីលើក្បាច់នេះ មានរូបសញ្ញាអប់រំ យុវជន និងកីឡា និងមានឡេវរូបព្រះសង្ការពណ៌មាសមួយ នៅខាងលើរូបសញ្ញាអប់រំ យុវជន និងកីឡា។ នៅខាងក្រៅ មានក្បាច់ធ្មេញក្របី មួយខ្សែពណ៌មាសព័ទ្ធជុំវិញ។ ផ្ទៃខាងក្រៅនៃក្បាច់ធ្មេញក្របី មានខ្សែពួរវេញពណ៌មាសព័ទ្ធជុំវិញ ដែលមានលក្ខណៈសម្គាល់ខុសគ្នាបីយ៉ាង គឺៈ បីខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ និងមួយខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តម។

ខ្នាតសក្តិស្មាមានកំណត់ដូចខាងក្រោម ÷

- បាតធំប្រវែង ៦ សង់ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤,៤០ សង់ទីម៉ែត្រ នៅខាងចុងមានរាងជាមុំទាល
- បណ្តោយពីបាតលើដល់បាតក្រោមប្រវែង ១៣ សង់ទីម៉ែត្រ។

**២- អំពីសក្តិចុងកអាវសងខាង**

សក្តិចុងកអាវមានផ្ទៃកម្ទីពណ៌ខៀវទឹកប៊ិច រចនាតុបតែងដោយសន្លឹកភ្ញីទេសពណ៌មាសមួយទង មានផ្កាមួយ និងផ្លែពីរនៅបន្ទាប់ពីរូបសញ្ញាអប់រំ យុវជន និងកីឡា។ នៅផ្នែកខាងលើ និងចំហៀងខាងមុខ មានក្បាច់ធ្មេញក្របីពណ៌មាសមួយខ្សែ។ នៅខាងក្រៅស្របនឹងខ្សែនៃក្បាច់ធ្មេញក្របី មានខ្សែពួរវេញពណ៌មាស ដែលមានលក្ខណៈសម្គាល់ខុសគ្នា គឺៈ បីខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ និងមួយខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តម។

ខ្នាតសក្តិចុងកអាវមានកំណត់ដូចខាងក្រោម ÷

- រាងជាប្រលេឡូក្រាម
- បណ្តោយប្រវែង ៩ សង់ទីម៉ែត្រ
- ទទឹងប្រវែង ៣,៨ សង់ទីម៉ែត្រ។

**៣- អំពីសក្តិចុងដៃអាវទាំងសងខាង**

សក្តិចុងដៃអាវមានផ្ទៃខៀវទឹកប៊ិច។ នៅចំកណ្តាលនៃតួសក្តិ មានរូបសញ្ញាអប់រំ យុវជន និងកីឡា ដែលរចនា តុបតែងដោយសន្លឹកភ្ញីទេសពណ៌មាសបួនទង ពីរទងខាងលើវែង និងពីរទងខាងក្រោមខ្លី នៅអមសងខាងមានលក្ខណៈជាជញ្ជីងថ្លឹងស្មើ។ នៅលើទងទាំងបួន មានផ្កាបួន លើទងវែងពីរ លើទងខ្លីពីរ និងផ្លែម្ភៃពីរ នៅលើទងវែងដប់ប្រាំមួយ លើ

ROYAUME DU CAMBODGE

ទងខ្ចី ប្រាំមួយ ។ នៅផ្នែកខាងលើ និងចំហៀងសងខាង មានក្បាច់ផ្ចេញក្របីពណ៌មាសមួយខ្សែ ។ នៅខាងក្រៅស្របនឹងខ្សែនៃក្បាច់ផ្ចេញក្របី មានខ្សែពួរវេញពណ៌មាស ដែលមានលក្ខណៈសម្គាល់ខុសគ្នា គឺ : បីខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ និងមួយខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តម ។

ខ្នាតសក្តិចុងដៃអាវមានកំណត់ដូចខាងក្រោម ÷

- រាងជាបួនជ្រុងទ្រវែង
- បណ្តោយប្រវែង៣២ សង្ទីម៉ែត្រសម្រាប់បុរស
- ទទឹងប្រវែង៥ សង្ទីម៉ែត្រ ។

សក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស មានគំរូដូចក្នុងឧបសម្ព័ន្ធទី២ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៣ និងសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម មានគំរូដូចក្នុងឧបសម្ព័ន្ធទី៤ ។

**ខ- ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន**

សក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សម្រាប់មន្ត្រីក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មានលក្ខណៈទម្រង់ដូចគ្នាទាំងស្រុង ទៅនឹងមន្ត្រីក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ប៉ុន្តែក្បាច់ភ្ញីទេស ក្បាច់ផ្ចេញក្របី និងខ្សែពួរវេញ មានពណ៌ទឹកប្រាក់ ។ លក្ខណៈសម្គាល់ប្រភេទទាំងបី នៃឋានន្តរសក្តិមន្ត្រីក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន គឺ : ខ្សែពួរវេញពណ៌ទឹកប្រាក់បីខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស ពីរខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ និងមួយខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋាន ។

សក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស មានគំរូដូចក្នុងឧបសម្ព័ន្ធទី៥ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៦ និងសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មានគំរូដូចក្នុងឧបសម្ព័ន្ធទី៧ ។

ដោយឡែក សក្តិស្មា សក្តិចុងកអាវ សក្តិចុងដៃអាវទាំងសងខាង សម្រាប់នារី មានទំហំដូចខាងក្រោមនេះ ÷

- ចំពោះសក្តិស្មា អាចមានទំហំ ៨០% ៨៥% ៩០% នៃទំហំសក្តិស្មាបុរស អាស្រ័យលើមាឌរបស់នារី
- សក្តិចុងកអាវ មានទំហំទទឹង៣ សង្ទីម៉ែត្រ ទៅ៣,៥០ សង្ទីម៉ែត្រ អាស្រ័យលើកម្ពស់របស់នារី
- សក្តិចុងដៃអាវអាចមានទំហំស្មើនឹង៧០% ទៅ ៧៥%នៃទំហំសក្តិចុងដៃអាវបុរស អាស្រ័យលើមាឌរបស់នារី ។

## ផ្នែកទី ២

## ទំពីឯកសណ្ឋាន

**មាត្រា៤.-**

ប្រភេទឯកសណ្ឋាន សម្រាប់មន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ត្រូវបានកំណត់ដូចតទៅ ÷

ROYAUME DU CAMBODGE

**ក- ឯកសណ្ឋានផ្លូវការ**

**១- ចំពោះបុរស**

- អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិ និងគ្មានផែកខ្នង។ នៅខាងមុខ មានបិទឡេវរូបព្រះសង្ហារចំនួន៧គ្រាប់ ពណ៌មាស សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងពណ៌ប្រាក់ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងមានហោប៉ៅចំនួន៤ គឺ : ហោប៉ៅខាងលើពីរ និងហោប៉ៅ ខាងក្រោមពីរ ដេរបង្កប់ មានគម្របរាងស្លឹកពោធិ៍។ នៅលើគម្របហោប៉ៅនីមួយៗ មានចោះរន្ធបិទឡេវរូបព្រះសង្ហារមួយគ្រាប់ ពណ៌មាស ឬ ពណ៌ប្រាក់ ស្របតាមប្រភេទក្របខ័ណ្ឌនីមួយៗ

- ខោជើងវែងពណ៌ស ស្បែកជើងឃ្លុបពណ៌ខ្មៅ ចងខ្សែ និងស្រោមជើងពណ៌ខ្មៅ។

**២- ចំពោះស្ត្រី**

- អាវជីបរាងពណ៌ស ដោយប្រើប្រភេទកំណាត់ ដូចឈុតអាវរបស់បុរស កតាំងដៃវែងត្រឹមភ្នែកគោលដៃ គ្មានផែកខ្នង កាត់រាងអាវធំ នៅខាងមុខមានបិទឡេវរូបព្រះសង្ហារចំនួន៥ គ្រាប់ ពណ៌មាស សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងពណ៌ប្រាក់ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន។ ចុងកអាវមានសក្តិលើស្មាមានបន្ទះសម្រាប់ដាក់សក្តិ និងមានហោប៉ៅចំនួន៤ ដេរបង្កប់ គឺ : ហោប៉ៅលើពីរ និងហោប៉ៅក្រោមពីរ ដែលមានគម្របរាងស្លឹកពោធិ៍ ហើយ នៅពីលើគម្របនីមួយៗ មានចោះរន្ធបិទឡេវរូបព្រះសង្ហារមួយគ្រាប់ ពណ៌មាស ឬ ពណ៌ប្រាក់ ស្របតាមប្រភេទក្របខ័ណ្ឌនីមួយៗ

- សំពត់ផាមួងពណ៌ខៀវទឹកប៊ិច រងជើងមានចាក់ខ្សែសយពណ៌មាស ឬ ពណ៌ប្រាក់ ស្របតាមប្រភេទក្របខ័ណ្ឌនីមួយៗ។ សំពត់នេះមានសម្រុងលើភ្នែកគោលនៃស្មងជើង ប្រវែងពី១០ ទៅ១៥ សង់ទីម៉ែត្រ អនុលោមតាមមាឌ និងកម្ពស់របស់នារី

- ស្បែកជើងអេស្កាប៉ាងពណ៌ស។

ឯកសណ្ឋានផ្លូវការសម្រាប់បុរស និងស្ត្រី នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម មានគំរូដូចក្នុងឧបសម្ព័ន្ធទី៨ និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មានគំរូដូចក្នុងឧបសម្ព័ន្ធទី១០ នៃព្រះរាជក្រឹត្យនេះ។

**ខ- ឯកសណ្ឋានប្រពៃណីជាតិ**

**១- ចំពោះបុរស**

- អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិ និងគ្មានផែកខ្នង។ នៅខាងមុខមានបិទឡេវរូបព្រះសង្ហារចំនួន៧ គ្រាប់ ពណ៌មាស សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងពណ៌ប្រាក់ សម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងមានហោប៉ៅចំនួន៤ គឺ : ហោប៉ៅខាងលើពីរ និងហោប៉ៅខាងក្រោមពីរ ដេរបង្កប់ មានគម្របរាងស្លឹកពោធិ៍។ នៅលើគម្របហោប៉ៅនីមួយៗ មានចោះរន្ធបិទឡេវរូបព្រះសង្ហារ ចំនួនមួយគ្រាប់ ពណ៌មាស ឬ ពណ៌ប្រាក់ ស្របតាមប្រភេទក្របខ័ណ្ឌនីមួយៗ

- សំពត់ផាមួងចងក្បិន មានពណ៌ស្របតាមថ្ងៃដែលប្រើប្រាស់

- ស្បែកជើងឃ្លុបពណ៌ខ្មៅ កខ្លី មានចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ដល់ក្បាលជង្គង់ ។

ROYAUME DU CAMBODGE

**២- ចំពោះស្ត្រី**

- អាវជីបរាង ធ្វើអំពីកំណាត់ចាក់ពណ៌ស មានកភាងអប្សរា ដៃវែងត្រឹម ៣/៤ រូតខ្ទង់បន្តិច
- ពានាក្រមាតាមពណ៌សំពត់ ឬ តាមពិធីការកំណត់
- សំពត់ផាមួងចងក្បិន មានពណ៌ស្របតាមថ្ងៃដែលប្រើប្រាស់
- ស្បែកជើងអេស្កាប៉ាំងពណ៌ស
- កាបូបយួរដៃពណ៌ស ឬ ពណ៌ខ្មៅ ។

ឯកសណ្ឋានប្រពៃណីសម្រាប់បុរស និងស្ត្រី នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម មានគំរូដូចក្នុងឧបសម្ព័ន្ធទី៩ និង ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មានគំរូដូចក្នុងឧបសម្ព័ន្ធទី១១ នៃព្រះរាជក្រឹត្យនេះ ។

## ផ្នែកទី៣

## អំពីសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា

**មាត្រា៥.-**

សក្តិខ្ទាស់លើអាវ ឬ ក្រមាពានា មានរាងពងក្រពើ ដែលមានរូបសញ្ញាអប់រំ យុវជន និងកីឡា។ នៅខាងក្នុងចំកណ្តាល ធ្វើអំពីដីរវឹងថ្លា ចាក់ស្រោបពីក្រៅរូបសញ្ញាអប់រំ យុវជន និងកីឡា និងមានផ្ទៃពណ៌ខៀវទឹកប៊ិច ។ សក្តិខ្ទាស់លើអាវ ឬ ក្រមាពានា មានទំហំ និងខ្នាតទទឹងប្រវែង៣ សង់ទីម៉ែត្រ មានខ្សែព័ទ្ធជុំវិញទៅតាមប្រភេទក្របខ័ណ្ឌ និងឋានន្តរសក្តិនៃអង្គមន្ត្រីនីមួយៗ។

សក្តិខ្ទាស់លើអាវនេះ សម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ ។ សក្តិនេះក៏សម្រាប់ខ្ទាស់លើក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណី ។

សក្តិខ្ទាស់លើអាវ ឬ ក្រមាពានា មានគំរូដូចក្នុងឧបសម្ព័ន្ធទី១២ នៃព្រះរាជក្រឹត្យនេះ ។

## ផ្នែកទី៤

## អំពីការប្រើប្រាស់ឯកសណ្ឋាន

**មាត្រា៦.-**

ការប្រើប្រាស់ឯកសណ្ឋាន សម្រាប់មន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀន ទាំងពីរកម្រិត ត្រូវបានកំណត់ដូចខាងក្រោម ÷

- ឯកសណ្ឋានផ្លូវការ សម្រាប់ប្រើប្រាស់ក្នុងពិធីបុណ្យជាតិ និងពិធីការផ្សេងៗ
- ឯកសណ្ឋានប្រពៃណី សម្រាប់ប្រើប្រាស់ក្នុងពិធីបុណ្យប្រពៃណីជាតិ និងបុណ្យសាសនា ដែលប្រារព្ធធ្វើនៅក្នុងព្រះបរមរាជវាំង ក្នុងទីវត្តអារាម ឬ ទីកន្លែងផ្សេងៗ។

## ជំពូកទី ៤

## របបកំណត់ឯកសណ្ឋាន និងសញ្ញាសក្តិ

ROYAUME DU CAMBODGE

**មាត្រា៧.-**

ត្រូវបានផ្តល់ជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋានផ្លូវការមួយសម្រាប់ និងឯកសណ្ឋានប្រពៃណីមួយសម្រាប់ ព្រមទាំងសក្តិខ្ចាស់លើអាវ ឬ ក្រមាពានា និងសម្ភារៈផ្សេងៗទៀត ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ។ ឯកសណ្ឋានទាំងនេះត្រូវផ្តល់ជូនក្នុងរយៈពេលបីឆ្នាំម្តង។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ សីហា ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

នស/រកត.០៧០៨.៣៤៥

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ៣៣៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] ចិនកេន**

ឧបសម្ព័ន្ធទី.០១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣២២ ចុះថ្ងៃទី..១...ខែសីហា ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្លាស់លើអាវ ឬ ក្រមាពាទា សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

ក្រសួងអប់រំយុវជននិងកីឡា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

9/20/

ឧបសម្ព័ន្ធទី.១២. នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៧២៥. ចុះថ្ងៃទី.១...ខែសីហា.ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្វាស់លើអាវ ឬ ក្រមាពានា
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

## សញ្ញាសក្តិសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស

សក្តិកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ROYAUME du CAMBODGE • LE MINISTRE du PALAIS ROYAL •

ឧបសម្ព័ន្ធទី.០៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៧២៥ ចុះថ្ងៃទី.១...ខែសីហា ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ចាស់លើអាវ ឬ ក្រមាពានា សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

## សញ្ញាសក្តិសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ

សក្តិករអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី.០៤. នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨៨០៧/៧២៤ចុះថ្ងៃទី..៧...ខែសីហា.ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

**សញ្ញាសក្តិសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម**

**សក្តិកអាវ**



**សក្តិស្មា**



**សក្តិចុងដៃអាវ**



ឧបសម្ព័ន្ធទី.០៥. នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៧២៤ ចុះថ្ងៃទី.១...ខែសីហា.ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្នាស់លើអាវ ឬ ក្រមាពានា
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

## សញ្ញាសក្តិសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស

សក្តិកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី.០៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣២៤ ចុះថ្ងៃទី..១..ខែសីហា.ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា
សម្រាប់មន្ត្រីអប់រំ គ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

## សញ្ញាសក្តិសម្រាប់សម្គាល់គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ

សក្តិករអាវ



សក្តិស្មា



សក្តិចុងដៃអាវ





ROYAUME du CAMBODGE * LE MINISTRE du PALAIS ROYAL *

ឧបសម្ព័ន្ធទី.០៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣២៥ ចុះថ្ងៃទី..១..ខែសីហា.ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពាទា សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

## សញ្ញាសក្តិសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន



សក្តិកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី.១៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣២៥ចុះថ្ងៃទី..១..ខែសីហា.ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពាទា សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

## ឯកសណ្ឋានផ្លូវការសម្រាប់សម្គាល់ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

16/20

ឧបសម្ព័ន្ធទី.១៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៧២៥ចុះថ្ងៃទី..១..ខែសីហា.ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

**ឯកសណ្ឋានប្រពៃណីសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម**



ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

17/20

ឧបសម្ព័ន្ធទី.១០ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣២២ចុះថ្ងៃទី.១...ខែសីហា.ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

**ឯកសណ្ឋានផ្លូវការសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន**



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

18/20

ឧបសម្ព័ន្ធទី.១១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៧២៥ចុះថ្ងៃទី.១...ខែសីហា.ឆ្នាំ២០០៧
ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្ទាស់លើអាវ ឬ ក្រមាពានា
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

**ឯកសណ្ឋានប្រពៃណីសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន**



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

19/20

ឧបសម្ព័ន្ធទី.១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៧២៤ ចុះថ្ងៃទី..១..ខែសីហា.ឆ្នាំ២០០៧
ស្ដីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្នាស់លើអាវ ឬ ក្រមាពានា
សម្រាប់មន្ត្រីអប់រំ ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋាន

## សក្តិខ្នាស់លើអាវ ឬ ក្រមាពានាសម្រាប់សម្គាល់ក្របខ័ណ្ឌគ្រូបង្រៀន

**កម្រិតឧត្តមដើមខ្សែពិសេស**




**កម្រិតឧត្តមដើមខ្សែ**



**កម្រិតឧត្តម**



**កម្រិតមូលដ្ឋានដើមខ្សែពិសេស**




**កម្រិតមូលដ្ឋានដើមខ្សែ**



**កម្រិតមូលដ្ឋាន**



ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

20/29